ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

BThyna

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ១៨៧ ប្រក.កសក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបង្កើតកសិដ្ឋានចិញ្ចឹមសត្វឈ្មោះ ហ្វ្រឹនម៉ាក់

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញពាក្យស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វរបស់លោកស្រី ឡេក ស៊ីណាង ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ដែលមានចំណារបញ្ជូនលេខ ០៣៣ សរសណ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៤ របស់អភិបាលខេត្តកំពង់ស្ពឺ
- តាមសំណើរបស់ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

## សម្រេច

**ប្រការ១** : អនុញ្ញាតឱ្យលោកស្រី **ឡេក ស៊ីណាង** ភេទស្រី អាយុ ២២ឆ្នាំ ទីលំនៅភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បង្កើតកសិដ្ឋានចិញ្ចឹមសត្វឈ្មោះ **ហ្វ្រឹនម៉ាក់** ដើម្បីចិញ្ចឹមជ្រូក និង គោ មានទីតាំងនៅភូមិទី៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**ប្រការ២** : កសិដ្ឋានចិញ្ចឹមសត្វ ដែលកំណត់ដោយប្រការ១ខាងលើនេះ ត្រូវបានរៀបចំឡើងតាមគំរិត ចិញ្ចឹម ជាលក្ខណៈឧស្សាហកម្ម ។

**ប្រការ៣** : កសិដ្ឋានចិញ្ចឹមសត្វនេះ ត្រូវចុះកិច្ចសន្យាបច្ចេកទេសជាមួយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ឱ្យបានច្បាស់លាស់ និង មានអ្នកទទួលខុសត្រូវបច្ចេកទេសថ្នាក់បរិញ្ញាវិទ្យាសាស្ត្រផ្នែកផលិតកម្ម និង បសុព្យាបាលម្នាក់ដែលមានអតីតភាពការងារមិនតិចជាង ៣ឆ្នាំ ហើយត្រូវបាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ទទួលស្គាល់ ។

**ប្រការ៤** : សាមីកសិដ្ឋានដែលបានទទួលការអនុញ្ញាត ត្រូវប្រតិបត្តិតាមល័ក្ខខ័ណ្ឌខាងក្រោមនេះ :

ក-គោរពល័ក្ខខ័ណ្ឌបច្ចេកទេសអាជីវកម្ម ការចិញ្ចឹមសត្វ ដែលរដ្ឋបានកំណត់ ។

ខ-គោរពបទប្បញ្ញត្តិស្តីពីវិធានការការពារជម្ងឺសត្វ និង វិធានការអនាម័យបសុពេទ្យអោយបានត្រឹមត្រូវ ។

គ-បង់អាករអនាម័យសត្វតាមច្បាប់រដ្ឋកំណត់ ។

ឃ-ត្រូវមានបទបញ្ជាស្តីពីវិធីសាស្ត្រនៃការគ្រប់គ្រងច្បាស់លាស់ ដើម្បីជៀសវាងការបង្កជម្ងឺឆ្លងរាតត្បាតផ្សេងៗ ។

ង-ត្រូវអនុញ្ញាតឱ្យអ្នកបច្ចេកទេស សិស្ស និង និស្សិតចុះសហការ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និង ដកស្រង់បទពិសោធន៍ និង ធ្វើកម្មសិក្សាលើការងារបច្ចេកទេស ។

__ប្រការ៥__ : កសិដ្ឋានចិញ្ចឹមសត្វឈ្មោះ **ហ្វ្រីនម៉ាត់** មានសិទ្ធិចិញ្ចឹមជ្រូក និង គោគ្រប់ប្រភេទ លក់ផលិតផលដែល កសិដ្ឋានផលិតបាន នៅទីផ្សារក្នុងប្រទេស ។

__ប្រការ៦__ : រាល់ការនាំចូលថ្នាំព្យាបាល វ៉ាក់សាំង សម្ភារៈបរិក្ខារ មធ្យោបាយផលិត និង ពូជសត្វ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងត្រូវបង់ពន្ធផ្សេងៗតាមច្បាប់កំណត់ ។

__ប្រការ៧__ : ប្រកាសនេះ មានតំលៃអនុវត្តសំរាប់រយៈពេល ៥ឆ្នាំ ( ប្រាំ) គិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

__ប្រការ៨__ : ប្រកាសនេះ ត្រូវទុកជានិរាករណ៍ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងករណីដែលពិនិត្យឃើញថា សាមីកសិដ្ឋានបានប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ ។

__ប្រការ៩__ : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋាននីតិកម្ម កសិកម្ម ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្តកំពង់ស្ពឺ និង ម្ចាស់កសិដ្ឋានសាមី ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៤

**រដ្ឋមន្ត្រី**

ច័ន្ទ សារុន

__**កន្លែងទទួល:**__

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-សាលាខេត្តកំពង់ស្ពឺ

"__ដើម្បីជូនជ្រាប__"

-ដូចប្រការ៩

"__ដើម្បីអនុវត្ត__"

-ឯកសារ-កាលប្បវត្តិ